ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 05 / 2016
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម យូរ ឧត្តរា |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៦ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

## សេចក្តីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧ (៤) សុំឲ្យទទួលយកឯកសារចំនួន ២៩ ទាក់ទងនឹងសក្ខីកម្មរបស់អ្នកជំនាញ 2-TCE-95

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើចំនួនពីរ អនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកឯកសារជាឯកសារភ័ស្តុតាងដាច់ដោយឡែកពីគ្នា ចំនួន ១៥ និងចំនួន ១៤ ដែលជាប់ពាក់ព័ន្ធនឹងសក្ខីកម្មរបស់ អ៊ីសា ឧស្មាន ("លោក ឧស្មាន") ដែលមេធាវីការពារក្តី នួន ជា បានដាក់នៅថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ("សំណើលើកទីមួយ")[1] និងនៅថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ("សំណើលើកទីពីរ")[2]។

២. អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់របស់មេធាវីការពារក្តី នួន ជា រួមទាំងចម្លើយតបពីភាគីផ្សេងទៀតទៅលើសំណើទាំងពីរនេះកាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦[3]។ អង្គជំនុំជម្រះបានយល់ព្រមតាមចំណុចមួយចំនួននៃសំណើទី១ និងសំណើទី២ នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដោយទទួលយកឯកសារចំនួន ១៨ និងបានកំណត់ឯកសារទាំងនោះជាឯកសារ E3[4]។ តទៅនេះ អង្គជំនុំជម្រះផ្តល់សំអាងហេតុសម្រាប់សេចក្តីសម្រេចរបស់ខ្លួន។

## ២. សារណា

---

[1] សំណើលើកទីមួយរបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) ស្នើសុំឱ្យទទួលយកឯកសារចំនួន ១៥ ទាក់ទងនឹងសក្ខីកម្មរបស់អ្នកជំនាញ អ៊ីសា ឧស្មាន (2-TCE-95) (អំពីប្រវត្តិ ភាពឯករាជ និងភាពមិនលម្អៀង និង ចំនួនមនុស្សស្លាប់) ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E367/4 កថាខណ្ឌ ៣៧។

[2] សំណើលើកទីពីររបស់ នួន ជា អនុលោមតាមវិធាន ៨៧(៤) សុំទទួលយកឯកសារជាឯកសារភ័ស្តុតាងចំនួន ១៤ ដែលពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់អ្នកជំនាញ អ៊ីសា ឧស្មាន (2-TCE-95) (ទាក់ទងនឹងខ្មែរស ខ្មែរសេរី និង Les Kosem) ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E367/5 កថាខណ្ឌ ៣០។

[3] ប្រតិចារឹកសវនាការ ថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ទំព័រ ៧៧ ដល់ ៧៩។

[4] សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំឱ្យទទួលយកឯកសារពាក់ព័ន្ធនឹងសក្ខីកម្មរបស់អ្នកជំនាញ 2-TCE-95 ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E367/7 កថាខណ្ឌ ២។ ឯកសារខាងក្រោមនេះត្រូវបានទទួលយកពីសំណើលើកទីមួយ និងត្រូវបានចាត់ប្រភេទជាឯកសារ E3 ដូចតទៅ៖ ឯកសារ E367/4.1.1 (E3/9678); E367/4.1.3 (E3/9679); E367/4.1.4 (E3/9680); E367/4.1.6 (E3/9681); E367/4.1.7 (E3/9682); E367/4.1.9 (E3/9683); E367/4.1.10 (E3/9684); E367/4.1.11 (E3/9685) និង E367/4.1.12 (E3/9686)។ ឯកសារខាងក្រោមនេះត្រូវបានទទួលយកពីសំណើលើកទីពីរ និងត្រូវបានចាត់ប្រភេទជាឯកសារ E3 ដូចតទៅ៖ ឯកសារ E367/5.1.1 (E3/9687); E367/5.1.2 (E3/9688); E367/5.1.6 (E3/9689); E367/5.1.7 (E3/9690); E367/5.1.8 (E3/9691); E367/5.1.9 (E3/9692); E367/5.1.10 (E3/9693); E367/5.1.11 (E3/9694) និង E367/5.1.12 (E3/9695)។ ដើម្បីជួយសម្រួលដល់ការយោង នៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំជម្រះនឹងយោងដល់ឯកសារទាំងអស់ដែលភាគីបានស្នើសុំឱ្យទទួលយក ទៅតាមលេខយោងដើមរបស់ឯកសារទាំងនេះ។

៣. សំណើលើកទីមួយ ទាក់ទិននឹងឯកសារចំនួន៣ប្រភេទ។ ឯកសារប្រភេទទី I រួមមាន ខ្សែវីដេអូមួយដែលពាក់ព័ន្ធនឹងប្រវត្តិផ្ទាល់ខ្លួន និងសាវតារការងាររបស់លោក ឧស្មាន (ឯកសារ E367/4.1.1) ដែលមេធាវីការពារក្តី នួន ជា លើកឡើងថា គឺជាប់ពាក់ព័ន្ធនឹងវិធីសាស្ត្ររបស់លោក ឧស្មាន និងតម្លៃជាភស្តុតាងនៃសៀវភៅ ការធ្វើបទសម្ភាសន៍ និងភស្តុតាងរបស់គាត់[5]។ មេធាវីការពារក្តី នួន ជា លើកឡើងបន្ថែមថា លោក ឧស្មាន អាចមើលឃើញនៅក្នុងខ្សែវីដេអូ ហើយថា ខ្សែវីដេអូនោះមានសញ្ញាណនៃយថាភាព និងភាពជឿជាក់បានដែលជាបុរេលក្ខខណ្ឌ[6]។

៤. ឯកសារប្រភេទទី II រួមមាន ឯកសារចំនួនបី ដែលត្រូវបានអះអាងថាជាប់ពាក់ព័ន្ធទៅនឹងឯករាជ្យភាព ភាពមិនលម្អៀង និងការចូលរួមរបស់លោក ឧស្មាន ក្នុងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២/០២ ៖ សេចក្តីប្រកាសជ្រើសរើសបុគ្គលិករបស់ UNAKRT (ឯកសារ E367/4.1.2) បញ្ជីឈ្មោះសាក្សីរបស់ ក.ស.ច.ស ដែលត្រូវបានស្តាប់ចម្លើយ ដោយមានវត្តមានលោក ឧស្មាន នៅចន្លោះពីថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៧ ដល់ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (ឯកសារ E367/4.1.3) និង អត្ថបទសារព័ត៌មានមួយដែលលោក ឧស្មាន បានសរសេរនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ (ឯកសារ E367/4.1.4)[7]។ មេធាវីការពារក្តី នួន ជា អះអាងថា ឯកសារទាំងនេះមានសញ្ញាណនៃភាពជឿជាក់បាន *តាមការវិភាគបឋម*[8]។ ឯកសារ E367/4.1.2 និង E367/4.1.3 គឺជាឯកសារជាផ្លូវការដែលយកពីគេហទំព័រផ្លូវការរបស់ UNAKRT និង ក.ស.ច.ស ដាច់ៗពីគ្នា។ ឯកសារ E367/4.1.4 ត្រូវបានបោះពុម្ពផ្សាយដោយកាសែតដែលមានការទទួលស្គាល់ និងល្បីល្បាញ ហើយលោក ឧស្មាន ខ្លួនឯងនឹងអាចផ្តល់សក្ខីកម្មថា គាត់ពិតជាបាននិពន្ធអត្ថបទនេះមែន[9]។

៥. ឯកសារប្រភេទទី III រួមមានអត្ថបទស្រាវជ្រាវចំនួន ១១ ដែលត្រូវបានសរសេរនៅចន្លោះពីឆ្នាំ ១៩៨៨ ដល់ឆ្នាំ ២០១៥ ជាប់ទាក់ទិនទៅនឹងការប្រព្រឹត្តចំពោះជនជាតិចាមក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ដោយរួមទាំងចំនួនអ្នកស្លាប់នៅក្នុងសហគមន៍នោះ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អន្តរជាតិជាទូទៅ (ឯកសារ E367/4.1.5 ដល់ E367/4.1.15)។ អត្ថបទទាំងនោះត្រូវ

---

[5] សំណើលើកទីមួយ កថាខណ្ឌ ៤ ដល់ ៥។

[6] សំណើលើកទីមួយ កថាខណ្ឌ ៧។

[7] សំណើលើកទីមួយ កថាខណ្ឌ ៨ ដល់ ១២។

[8] សំណើលើកទីមួយ កថាខណ្ឌ ១២។

[9] សំណើលើកទីមួយ កថាខណ្ឌ ១២។

បានសរសេរដោយលោក ឧស្មាន, George Wright, Khuon Narim, Ben Kiernan, Michael Vickery, Philip Short, ទូច បូរ៉ា, Stéphanie Giry, Stuart A. Becker, Kevin Poniah និង Koam Chanrasmey និងជាផ្នែកនៃការពិភាក្សាដេញដោលក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវអំពីភាពជឿជាក់បាននៃការប៉ាន់ប្រមាណទៅលើការស្លាប់ និងរបួសនៅក្នុងសហគមន៍ចាមនោះ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ[10]។ មេធាវីការពារក្តី នួន ជា លើកឡើងថា អត្ថបទទាំងនេះជាប់ពាក់ព័ន្ធទៅនឹងការប៉ាន់ប្រមាណរបស់លោក ឧស្មាន ចំពោះការស្លាប់ជនជាតិចាមនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ហើយថា អត្ថបទទាំងនេះអាចជឿជាក់បាន *តាមការវិភាគបឋម* ដោយត្រូវបានសរសេរដោយអ្នកសារព័ត៌មាន និងអ្នកជំនាញ រួមទាំង លោក ឧស្មាន ហើយត្រូវបានបោះពុម្ពផ្សាយដោយប្រភពមួយចំនួនដែលមានភាពល្បីល្បាញ[11]។

៦. មេធាវីការពារក្តី នួន ជា លើកឡើងថា ឯកសារ E367/4.1.1, E367/4.1.14 និង E367/4.1.15 មិនអាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះក្តីទេ ហើយថា ឯកសារទាំង ១៥ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ រួមទាំងសៀវភៅរបស់លោក ឧស្មាន ដែលត្រូវបានទទួលយកជាឯកសារភស្តុតាង គឺឯកសារ E3/1822 និង E3/2653[12]។ ឯកសារដែលនៅសេសសល់ផ្សេងទៀតមិនអាចរកឃើញពីមុនទេ ដោយសារថាឯកសារទាំងនេះជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងឯករាជ្យភាព ចម្លើយ និងជំនាញរបស់លោក ឧស្មាន ដែលត្រូវបានអះអាង។ យោងតាមមេធាវីការពារក្តី នួន ជា បានបញ្ជាក់ថា លោក ឧស្មាន ទើបតែត្រូវបានចាត់តាំងជាអ្នកជំនាញកាលពីនៅថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ ហើយគាត់ត្រូវបានអនុញ្ញាតឲ្យមកផ្តល់សក្ខីកម្មជាផ្លូវការដោយអង្គការសហប្រជាជាតិ កាលពីថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦[13]។

៧. សំណើលើកទីពីរ ពាក់ព័ន្ធទៅនឹងឯកសារចំនួន ១៤ ដែលទាក់ទិននឹងចលនាឥស្លាមចំនួនបី ដែលត្រូវបានចាត់ទុកថា ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ នៅក្នុងពេលដែលមានការជាប់ពាក់ព័ន្ធគ្នា ដែលក្នុងនោះ មានឈ្មោះថា ខ្មែរស រណសិរ្សរួបរួមរំដោះជាតិ

---

[10] សំណើលើកទីមួយ កថាខណ្ឌ ១៥ ដល់ ៣២។

[11] សំណើលើកទីមួយ កថាខណ្ឌ ១៣ ដល់ ១៤, ៣៥ ដល់ ៣៦។

[12] សំណើលើកទីមួយ កថាខណ្ឌ ៥ និង ៣៣ ដល់ ៣៤។

[13] សំណើលើកទីមួយ កថាខណ្ឌ ១០ និង ៣៣។

សាសន៍ដែលត្រូវគេគាបសង្កត់ (“FULRO”) និងខ្មែរសេរី ហើយក្រុមទាំងនេះជាប់ពាក់ព័ន្ធយ៉ាងសំខាន់ជាមួយនឹងសហគមន៍ជនជាតិចាម។ឯកសារទាំងនេះក៏ជាប់ពាក់ព័ន្ធផងដែរទៅនឹង លន់ នល់ និងមន្ត្រីជាន់ខ្ពស់ជាជនជាតិចាមនៅក្នុងកងយោធពលខេមរភូមិន្ទ ឈ្មោះ LES Kosem និងទំនាក់ទំនងការទូតរបស់គាត់ជាមួយបណ្ដាប្រទេសមូស្លីមជាច្រើនទៀត[14]។ មេធាវីការពារក្ដី នួន ជា លើកឡើងថា សម្ភារៈនេះអាចផ្ដល់ព័ត៌មានស៊ីជម្រៅចំពោះមូលហេតុនានានៅខាងក្រោយការចោទប្រកាន់ពីការចាប់ខ្លួន ឬ ការសម្លាប់ប្រជាជនចាម ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដូច្នេះ វាជាប់ពាក់ព័ន្ធទៅនឹងការចោទប្រកាន់នានាទាក់ទិននឹងការប្រព្រឹត្តចំពោះជនជាតិចាម និងការចោទប្រកាន់ពីចេតនាប្រល័យពូជសាសន៍របស់ជនជាប់ចោទ[15]។ ជាងនេះទៀត សម្ភារៈនេះអាចពាក់ព័ន្ធផ្ទាល់ទៅនឹងសក្ខីកម្មរបស់លោក ឧស្មាន ក្នុងអំឡុងពេលសវនាការលើប្រធានបទស្ដីពីការប្រព្រឹត្តទៅលើជនជាតិចាម[16]។

៨. ឯកសារ E367/5.1.1 គឺជាកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទិត្យ ទុំ ដែលលោក ឧស្មាន សម្ភាសន៍នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៩៩ ដែលឯកសារនេះជាប់ពាក់ព័ន្ធទៅការបះបោររបស់ខ្មែរសប្រឆាំងទៅនឹងខ្មែរក្រហម រួមទាំងប្រធានបទផ្សេងៗទៀត[17]។ ឯកសារ E367/5.1.2 គឺជាចម្លើយសារភាពរបស់ ចឹក ប្រាហ៊ីម ដែលពិភាក្សាអំពីចលនា FULRO[18]។ ឯកសារ E367/5.1.3 គឺជាសំណេរប្លុក (blog entry) របស់ Jean-Michel Filippi ដែលពិភាក្សាពីចលនា FULRO ផងដែរ[19]។ ឯកសារ E367/5.1.4 គឺជាអត្ថបទមួយរបស់ Robert L. Turkoly-Joczic ដែលត្រូវបានបោះពុម្ពផ្សាយដោយ *Asian Affairs* ដែលពិភាក្សាអំពីចលនាខ្មែរសេរី[20]។ ឯកសារ E367/5.1.5 គឺជាអត្ថបទដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងកាសែតភ្នំពេញប៉ុស្ដិ៍ ដែលសង្ខេបពីប្រវត្តិ និងតួនាទីរបស់ឧត្ដមសេនីយ៍ LES Kosem ដែលវិភាគទៅលើសារទូរលេខការទូតរបស់

---

[14] សំណើលើកទីពីរ កថាខណ្ឌ ១, ៦ ដល់ ៧។

[15] សំណើលើកទីពីរ កថាខណ្ឌ ៥។

[16] សំណើលើកទីពីរ កថាខណ្ឌ ២៧។

[17] សំណើលើកទីពីរ កថាខណ្ឌ ១០។

[18] សំណើលើកទីពីរ កថាខណ្ឌ ១១។

[19] សំណើលើកទីពីរ កថាខណ្ឌ ១២។

[20] សំណើលើកទីពីរ កថាខណ្ឌ ១៣។

សហរដ្ឋអាមេរិក ដែលត្រូវបានផ្សព្វផ្សាយដោយ Wikileaks[21]។ ឯកសារពី E367/5.1.6 ដល់ E367/5.1.12 ជាសារទូរលេខសហរដ្ឋអាមេរិកក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលទទួលបានពីគេហទំព័រ Wikileaks[22]។ *ក្នុងចំណោមចំណុចផ្សេងទៀត* ឯកសារទាំងនោះជាប់ពាក់ព័ន្ធទៅនឹងទំនាក់ទំនងរបស់ លន់ នល់ និង LES Kosem ជាមួយសហរដ្ឋអាមេរិក ចលនា FURLO សហគមន៍ចាម និងរដ្ឋអ៊ីស្លាមមួយចំនួន រួមទាំងប្រទេសអារ៉ាប៊ីសាអ៊ូឌីត និងសកម្មភាពរបស់ពួកគេទាក់ទិនទៅនឹងសន្និសីទរបស់បណ្តារដ្ឋអ៊ីស្លាមនៅទីក្រុងគូឡាឡាំពួរ[23]។ ឯកសារ E367/5.1.13 គឺជាអត្ថបទមួយដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងកាសែត Cambodia Daily ដែលពិភាក្សាអំពីការបង្កើតគណៈកម្មាធិការបដិវត្តន៍ និងការជាប់ពាក់ព័ន្ធរបស់ លន់ នល់, លន់ ណុន និង LES Kosem ចំពោះការប៉ុនប៉ងធ្វើរដ្ឋប្រហារប្រឆាំងនឹងសម្តេចសីហនុ នៅឆ្នាំ ១៩៧០[24]។ ចុងក្រោយ ឯកសារ E367/5.1.14 គឺជាអត្ថបទមួយដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងកាសែត the Washington Post ដែលពិភាក្សាអំពីការបង្កើតចលនាខ្មែរស នៅតំបន់កំពង់ស[25]។

៩. មេធាវីការពារក្តី នួន ជា លើកឡើងថា ឯកសារទាំង ១៤ មានសញ្ញាណនៃភាពជឿជាក់បាន *តាមការវិភាគបឋម*។ ឯកសារទាំងអស់បានមកពីប្រភពដែលអាចជឿជាក់បាន ដូចជា៖ មជ្ឈមណ្ឌលឯកសារកម្ពុជា និងកាសែត អ្នកនិពន្ធ ឬ គេហទំព័រ ដែលមានភាពល្បីល្បាញ ហើយត្រូវបាននិពន្ធដោយអ្នកជំនាញនៅក្នុងវិស័យការងាររបស់ពួកគាត់[26]។ ឯកសារ E367/5.1.3, E367/5.1.5 និង E367/5.1.13 ត្រូវបានបោះពុម្ពផ្សាយក្រោយពេលមានការចាប់ផ្តើមការជំនុំជម្រះ ទោះបីឯកសារផ្សេងទៀតអាចរកបានមុនពេលចាប់ផ្តើមការជំនុះជម្រះក៏ដោយ។ ដោយពិចារណាថា ការបង្ហាញខ្លួនរបស់លោក ឧស្មាន ទើបតែត្រូវបានបញ្ជាក់នៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ហើយថាឯកសារទាំង ១៤ ត្រូវបានស្នើសុំឱ្យទទួលយកក្នុងគោលបំណងជាក់លាក់នៃការជំទាស់ទៅនឹងការ

---

[21] សំណើលើកទីពីរ កថាខណ្ឌ ១៤។

[22] សំណើលើកទីពីរ កថាខណ្ឌ 15-21.

[23] សំណើទី២ កថាខណ្ឌ ១៥ ដល់ ២១។

[24] សំណើលើកទីពីរ កថាខណ្ឌ ២២។

[25] សំណើលើកទីពីរ កថាខណ្ឌ ២៣។ អង្គជំនុំជម្រះកត់សម្គាល់ថា អត្ថបទដែលចុះផ្សាយដោយកាសែតវ៉ាស៊ីងតុនប៉ុស្តិ៍ហាក់ដូចជាយោងទៅដល់តំបន់កំពង់ចាម និងមិនយោងដល់តំបន់កំពង់សនោះទេ។

[26] សំណើលើកទីពីរ កថាខណ្ឌ ២៨ ដល់ ២៩។

លើកឡើង និងជំនាញរបស់លោក ឧស្មាន ហេតុដូច្នេះហើយ មេធាវីការពារក្ដី នួន ជា លើកឡើងថា ឯកសារទាំងនេះមិនត្រូវបានដាក់ឱ្យបានមុននោះទេ[27]។

១០. សហព្រះរាជអាជ្ញាអន្តរជាតិមិនជំទាស់ទៅនឹងការទទួលយកឯកសារ E367/4.1.1, E367/4.1.3, E367/4.1.4, E367/4.1.6, E367/4.1.7, E367/4.1.12 និងឯកសារ E367/4.1.14 ពីសំណើលើកទីមួយ និងឯកសារ E367/5.1.3 ពីសំណើលើកទីពីរ[28]។ ចំពោះឯកសារដែលនៅសេសសល់ផ្សេងៗទៀត សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ឯកសារទាំងនេះ គឺមានការជាប់ពាក់ព័ន្ធ (ឯកសារ E367/4.1.2 និង E367/4.1.15 ពីសំណើលើកទីមួយ និងឯកសារ E367/5.1.4, E367/5.1.5, E367/5.1.7 និង E367/5.1.8 ដល់ E367/5.1.13 ពីសំណើលើកទីពីរ) ទៅនឹងយោបល់ផ្ទាល់ខ្លួន លើបញ្ហាអង្គច្បាប់របស់បុគ្គលដែលពុំមានជំនាញផ្នែកច្បាប់ (ឯកសារ E367/4.1.5, E367/4.1.8, E367/4.1.9 ដល់ E367/4.1.11 និង E367/4.1.13 ពីសំណើលើកទីមួយ) មានតែជាភាសាខ្មែរ (ឯកសារ E367/5.1.1 និង E367/5.1.2 ពីសំណើលើកទីពីរ) គឺជាឯកសារដែលខ្លឹមសារនៃឯកសារទាំងនេះទទួលបានតាមរយៈការធ្វើទារុណកម្ម (ឯកសារ E367/5.1.2 ពីសំណើលើកទីពី) ឬ ពុំមានព័ត៌មានថ្មី (ឯកសារ E367/5.1.6 និង E367/5.1.14 ពីសំណើលើកទីពីរ)[29] ។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជំទាស់តែទៅនឹងឯកសារ E367/5.1.2 ពីសំណើលើកទីពីរ ដោយពួកគេលើកឡើងថា ឯកសារនេះ គួរតែត្រូវបានជំទាស់ដោយផ្អែកលើទម្លាប់អនុវត្តន៍ដែលមានរបស់អង្គជំនុំជម្រះ ទាក់ទិនទៅនឹងចម្លើយសារភាព[30]។ មេធាវីការពារក្ដី ខៀវ សំផន ពុំបានធ្វើសេចក្ដីសន្និដ្ឋានណាមួយទេ។

## ៣. ច្បាប់ជាធរមាន និងសំអាងហេតុ

១១. អនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង នៅគ្រប់ដំណាក់កាលនីតិវិធីនៃការជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង អាចទទួលយកគ្រប់ភស្តុតាងទាំងអស់ដែលចាត់ទុកថា មានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត ក្នុងករណីភស្តុតាងទាំងអស់នោះបំពេញនូវបទដ្ឋាន *ឋមា*នៃភាពពាក់ព័ន្ធ ភាពអាចទុកចិត្តបាន និងយថាភាព ស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងវិធាន

---

[27] សំណើលើកទីពីរ កថាខណ្ឌ ២៤។

[28] ប្រតិចារឹកសវនាការ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ទំព័រ ៧៩ ដល់ ៨២។

[29] ប្រតិចារឹកសវនាការ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ទំព័រ ៧៩ ដល់ ៨៣។

[30] ប្រតិចារឹកសវនាការ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ទំព័រ ៨៣ ដល់ ៨៤។

៨៧ (៣) នៃវិធានផ្ទៃក្នុង ។ អង្គជំនុំជម្រះនឹងធ្វើសេចក្ដីសម្រេចចំពោះការស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុងក៏ចែងតម្រូវផងដែរថា ភាគីណាមួយដែលបានស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដាក់សំណើត្រូវធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ភស្តុតាងដែលបានស្នើសុំនោះពុំអាចរកបាននៅមុនពេលការចាប់ផ្ដើមការជំនុំជម្រះ ឬមិនអាចរកឃើញ ទោះបីជាមានការខិតខំរកប្រកបដោយការយកចិត្តទុកដាក់យ៉ាងណាក៏ដោយ។ ទោះបីជាយ៉ាងនេះក៏ដោយ នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកភស្តុតាងដែលពុំបានបំពេញលក្ខខណ្ឌឱ្យបានគ្រប់គ្រាន់ រួមទាំង ក្នុងករណីដែលភស្តុតាងជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងសម្ភារៈដែលមានរួចជាស្រេចនៅចំពោះមុខអង្គជំនុំជម្រះ និងក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះជាមួយគ្នា ហើយក្នុងករណីដែលឯកសារដែលបានស្នើសុំនោះជាឯកសារដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃដើម្បីជៀសវាងកំហុសក្នុងការស្វែងរកយុត្តិធម៌[31]។

## ៣.១ ភាពទាន់ពេលវេលានៃសំណើសុំ

១២. ជាបញ្ហាបឋម អង្គជំនុំជម្រះសូមរម្លឹកថា តាមការអនុវត្តនាពេលកន្លងមក ជាធម្មតា គ្រប់ភាគីត្រូវដាក់សំណើសុំឱ្យទទួលយកឯសារថ្មី ដែលខ្លួនមានបំណងប្រើប្រាស់ក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្ម យ៉ាងហោចណាស់ ឱ្យបានពីរសប្ដាហ៍មុនពេលបុគ្គលនោះមកផ្ដល់សក្ខីកម្ម[32]។ ឯកសារដែលចោទជាបញ្ហានៅពេលនេះ ត្រូវបានស្នើសុំឱ្យទទួលយកដោយផ្អែកលើភាពពាក់ព័ន្ធនៃឯកសារដើម្បីសួរដេញដោលអ្នកជំនាញ អ៊ីសា ឧស្មាន ។ ទោះបីជា លោក ឧស្មាន គ្រោងនឹងបង្ហាញខ្លួនចាប់ពីថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៦ ក៏ដោយ ក៏សំណើសុំទាំងពីរទើបតែត្រូវបានដាក់ដាច់ដោយឡែកពីគ្នាកាលពីថ្ងៃទី០២ និងថ្ងៃទី០៣ ខែកុម្ភៈ តែប៉ុណ្ណោះ។ មេធាវីការពារក្ដី នួន ជា សន្និដ្ឋានថា សំណើសុំទាំងនេះមិនអាចត្រូវបានដាក់នៅមុននេះនោះទេ ដោយហេតុថា ក្នុងចំណោមហេតុផលផ្សេងៗ

---

[31] សូមមើលចម្លើយតប អនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង ទៅនឹងសំណើសុំរបស់ព្រះរាជអាជ្ញា នួន ជា និង ខៀវ សំផន (ឯកសារ E236/4/1 ឯកសារ E265 ឯកសារ E271 ឯកសារ E276 ឯកសារ E276/1) ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៣ កថាខណ្ឌ ២។

[32] សេចក្ដីសម្រេចលើសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុងចំពោះការទទួលយកឯកសារ ជាប់ពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥ ឯកសារ E337/3 កថាខណ្ឌ ៣។

ទៀត ការបង្ហាញខ្លួនរបស់ លោក ឧស្មាន ទើបតែត្រូវបានបញ្ជាក់កាលពីថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ នៅពេលដែលអង្គជំនុំជម្រះបានទទួលលិខិតលះបង់អភ័យឯកសិទ្ធិរបស់លោក ឧស្មាន ពីអង្គការសហប្រជាជាតិ[33]។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសូមរម្លឹកថា អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់កាលពីថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៥ រួចហើយថា អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់អ្នកជំនាញ ឧស្មាន លើប្រធានបទនៃការប្រព្រឹត្តលើជនជាតិចាម[34]។ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ អង្គជំនុំជម្រះបានច្រានចោលការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ចំពោះការចាត់តាំងលោក ឧស្មាន ជាអ្នកជំនាញ ហើយបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់គាត់[35]។ អង្គជំនុំជម្រះក៏កត់សម្គាល់ផងដែរថា នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យពន្លឿនការស្តាប់សក្ខីកម្មសាក្សីចំនួនពីររូប និងស្នើសុំឱ្យកោះហៅសាក្សីចំនួន ៤ រូបបន្ថែមទៀត សម្រាប់ប្រធានបទនៃការប្រព្រឹត្តមកលើជនជាតិចាមទោះបីជាបានដឹងថា "សាក្សីអ្នកជំនាញ Ysa Osman នឹងមកបង្ហាញខ្លួនក្នុងពេលឆាប់ៗក៏ដោយ"[36]។ ទោះបីជាលិខិតលះបង់អភ័យឯកសិទ្ធិពីអង្គការសហប្រជាជាតិដែលអនុញ្ញាតឱ្យ លោក ឧស្មាន ផ្តល់សក្ខីកម្មទើបតែត្រូវបានទទួលកាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ភាគីត្រូវបានជូនដំណឹងអំពីសេចក្តីសម្រេចស្តាប់សក្ខីកម្មរបស់លោក ឧស្មាន តាំងពីថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០១៥ មកម្លេះ។ អាស្រ័យហេតុនេះ ផ្ទុយទៅនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះយល់ឃើញថា សំណើសុំលើកទីមួយ និងលើកទីពីរ គួរតែត្រូវបានដាក់រយៈពេលពីរសប្តាហ៍មុនពេលលោក ឧស្មាន បង្ហាញខ្លួន។ ការខកខានមិនបានធ្វើដូច្នេះ

---

[33] សំណើសុំលើកទីមួយ កថាខណ្ឌ ៣៣។ សំណើសុំលើកទីពីរ កថាខណ្ឌ ២៥។ សូមមើលលិខិតដែលអ្នកច្បាប់របស់អង្គការសហប្រជាជាតិបានផ្ញើមកកាន់ប្រធានអង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សំណើសុំឱ្យមានការលះបង់អភ័យឯកសិទ្ធិលោក អ៊ីសា ឧស្មាន" ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ឯកសារ E367/3 ។ លិខិតលះបង់អភ័យឯកសិទ្ធិរបស់អង្គការសហប្រជាជាតិពីដំណើរការច្បាប់ត្រូវបានស្នើសុំដោយប្រធានអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៦ ដើម្បីអនុញ្ញាតឱ្យលោក ឧស្មាន ផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញនៅក្នុងការជំនុំជម្រះលើសំណុំរឿង ០០២/០២ (ឯកសារ E367/2)។

[34] អ៊ីមែលដែលមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនគ្រប់ភាគីទាំងអស់ ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៥។

[35] សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកជំនាញដែលមានរហស្សនាម 2-TCE-95 ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ E367 ទំព័រ ៧។

[36] សំណើបន្ទាន់ និងរួមគ្នារបស់ នួន ជា សុំឱ្យពន្លឿនសំណើពីររបស់ខ្លួនដែលបានស្នើរួចហើយ និងសុំឱ្យកោះហៅសាក្សីបន្ថែមបួនរូបពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាម ថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ E370 កថាខណ្ឌ ១៥។

នាំឱ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចពន្យារពេលការស្តាប់សក្ខីកម្មរបស់លោក ឧស្មាន រយៈពេលមួយថ្ងៃ ដើម្បីពិនិត្យទៅលើសំណើសុំចំនួនពីររបស់មេធាវីការពារក្តី និងបញ្ហាផ្សេងៗទៀតដែលកំពុងរង់ចាំសេចក្តីសម្រេច[37]។

១៣. អង្គជំនុំជម្រះក៏យល់ឃើញផងដែរថា សំណើសុំលើកទីមួយ និងសំណើសុំលើកទីពីរ ពុំត្រូវបានដាក់ទាន់ពេលវេលាកំណត់ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដូចដែលមេធាវីការពារក្តីបានទទួលស្គាល់នៅក្នុងសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ខ្លួននោះទេ[38]។ ទាក់ទងនឹងសំណើសុំលើកទីមួយ ឯកសារពាក់ព័ន្ធចំនួនប្រាំបួន (ឯកសារ E367/4.1.3 ឯកសារ E367/4.1.4 និងឯកសារ E367/4.1.6 ដល់ ឯកសារ E367/4.1.12) ត្រូវបានចុះកាលបរិច្ឆេទ ចន្លោះខែតុលា ឆ្នាំ១៩៨៨ និងថ្ងៃទី១៦ ខែ មីនា ឆ្នាំ ២០១០ ដូច្នេះ ឯកសារទាំងនេះ អាចរកបាននៅមុនពេលចាប់ផ្តើមការជំនុំជម្រះ[39]។ ឯកសារ E367/4.1.1 E367/4.1.2 ឯកសារ E367/4.1.5 និងឯកសារ E367/4.1.13 ដល់ ឯកសារ E367/4.1.15 មិនអាចរកបាននៅមុនពេលនៃការចាប់ផ្តើមការជំនុំជម្រះទេ ប៉ុន្តែការទទួលយកឯកសារទាំងនេះ ត្រូវបានស្នើសុំចន្លោះពីរយៈពេលប្រាំខែ រហូតទៅបួនឆ្នាំ ក្រោយពីការបោះពុម្ពផ្សាយ ឬ ក្រោយពេលមេធាវីការពារក្តីរកឃើញឯកសារទាំងនោះ[40]។ ដូច្នេះហើយ ចំណុចនេះបង្ហាញពីការខកខានមិនបានអនុវត្តការងារដោយមានការយកចិត្តទុកដាក់។

១៤. ចំពោះសំណើសុំលើកទីពីរ ឯកសារពាក់ព័ន្ធចំនួនបួន (ឯកសារ E367/5.1.1 ដល់ឯកសារ E367/5.1.2 ឯកសារ E367/5.1.4 និងឯកសារ E367/5.1.14) ត្រូវបានចុះកាលបរិច្ឆេទនៅចន្លោះថ្ងៃទី០៧ ខែតុលា ឆ្នាំ ១៩៧៣ និងថ្ងៃទី០៤ ខែធ្នូ ឆ្នាំ ១៩៩៩ ដូច្នេះ ឯកសារទាំងនេះអាចរកបានក្នុងរយៈពេលជាច្រើនឆ្នាំ មុនពេលចាប់ផ្តើមការជំនុំជម្រះ[41]។ ចំពោះឯកសារចំនួនដប់ដែលនៅសេសសល់ផ្សេងទៀត (ឯកសារ E367/5.1.3 និងឯកសារ E367/5.1.5 ដល់ឯកសារ E367/5.1.13) អង្គជំនុំជម្រះកត់សម្គាល់ថា ឯកសារទាំងនោះមិនអាចរកបាននៅមុនពេលចាប់

---

[37] អ៊ីមែលដែលមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូនគ្រប់ភាគីទាំងអស់ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦។

[38] ប្រតិចារឹក ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ទំព័រ ១០៥។

[39] សំណើសុំលើកទីមួយ, កថាខណ្ឌ ៨-៩, ១៦-២៨។

[40] សំណើសុំលើកទីមួយ, កថាខណ្ឌ ៤, ១៥, ៣០-៣២ ។ ការពន្យារពេលក្នុងការស្នើសុំទទួលយកឯកសារទាំងនេះមានដូចខាងក្រោម៖ ឯកសារ E367/4.1.1 (១៨ ខែ) ឯកសារ E367/4.1.2 (៧ ខែ) ឯកសារ E367/4.1.5 (៥ ខែ) ឯកសារ E367/4.1.13 (១៧ ខែ) ឯកសារ E367/4.1.14 (៤ ឆ្នាំ និង ២ ខែ) និងឯកសារ E367/4.1.15 (២៣ ខែ)។

[41] សំណើសុំ, កថាខណ្ឌ ១៣, ២៣ និងឯកសារភ្ជាប់ ១-២ ។

ផ្ដើមការជំនុំជម្រះនាពេលបច្ចុប្បន្ននេះទេ ដោយសារតែឯកសារទាំងនេះត្រូវបានបោះពុម្ពផ្សាយ ឬ ធ្លាប់ត្រូវបានចាត់ទុកថាជាឯកសារសម្ងាត់ (ចំពោះសារទូរលេខការទូត) នាពេលក្រោយមក។ ទោះបីយ៉ាងណាក៏ដោយ សំណើសុំឱ្យទទួលយកឯកសារទាំងនេះត្រូវបានធ្វើឡើងនៅប្រហែលជាក្នុងរយៈពេលពីដប់ខែរហូតដល់ជិតបួនឆ្នាំក្រោយពេលឯកសារទាំងត្រូវបានបោះពុម្ពផ្សាយ ឬ ក្រោយពេលមេធាវីការពារក្ដីរកឃើញ[42]។ ការពន្យល់របស់មេធាវីការពារក្ដី នួន ជា ដែលថា កង្វះធនធាននោះ បានរាំងការដាក់ឯកសារទាំងនេះមិនឱ្យបានលឿនជាងនេះ និងថា ការដាក់សំណើសុំនៅដំណាក់កាលដំបូង ពុំប្រាកដថាធ្វើឱ្យអង្គជំនុំជម្រះចេញសេចក្ដីសម្រេចទាន់ពេលវេលានោះទេ ហេតុដូច្នេះ ពុំធ្វើឱ្យអង្គជំនុំជម្រះជឿជាក់បានឡើយ[43]។

## ៣.២. សំណើសុំលើកទីមួយ

១៥. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារ E367/4.1.1 មានការជាប់ពាក់ព័ន្ធ ព្រោះថាឯកសារនេះទាក់ទងទៅនឹងជីវប្រវត្តិរបស់លោក ឧស្មាន និងជំនាញរបស់លោក។ ឯកសារ E367/4.1.3 ជាប់ពាក់ព័ន្ធដោយឯកសារនេះបង្ហាញពីភារកិច្ចស៊ើបអង្កេតរបស់អ្នកជំនាញ ក្នុងតួនាទីគាត់ជាបុគ្គលិកមួយរូបនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក ។ ឯកសារ E367/4.1.4 ឯកសារ E367/4.1.6 ឯកសារ E367/4.1.7 ឯកសារ E367/4.1.9 និងឯកសារ E367/4.1.10 ដល់ឯកសារ E367/4.1.12 ផ្ដល់ភ័ស្ដុតាងពាក់ព័ន្ធដែលលើសពីទស្សនៈយល់ឃើញផ្ទាល់ខ្លួន ស្ដីពីនិយមន័យនៃអំពើប្រល័យពូជសាសន៍ដែលត្រូវបានលើកឡើងដោយអ្នកនិពន្ធ ឯកសារ E367/4.1.9 ដល់ឯកសារ E367/4.1.11 ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានអះអាង។ ឯកសារទាំងនេះទាក់ទងនឹងការប៉ាន់ប្រមាណអំពីចំនួនជនជាតិចាមដែលបានស្លាប់ និងរបួសនៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ប្រភពនៃការប៉ាន់ប្រមាណទាំងនេះ និងការវាយតម្លៃលើវិធី-សាស្ត្រដែលបានប្រើប្រាស់ដោយអ្នកជំនាញ គឺមានលក្ខណៈខុសៗគ្នានៅពេលប្រមូលទិន្និន័យ និងធ្វើសេចក្ដីសន្និដ្ឋាន។ ឯកសារទាំងអស់ខាងលើអាចទុកចិត្តបានដោយសារថា លោក ឧស្មាន គឺជាបុគ្គលដែលយើងស្គាល់នៅក្នុងឯកសារទាំងនោះ ឬ ជាអ្នកនិពន្ធឯកសារមួយចំនួន ឬ ក៏ដោយសារសេចក្ដី

---

[42] សំណើសុំ, កថាខណ្ឌ ១២, ១៤-២២ ។ ការពន្យារពេលក្នុងការស្នើសុំការទទួលយកឯកសារទាំងនេះមានដូចខាងក្រោម៖ ឯកសារ E367/5.1.3 (៣ ឆ្នាំ ១០ ខែ) ឯកសារ E367/5.1.5 ដល់ ឯកសារ E367/5.1.12 (២ ឆ្នាំ ១០ ខែ) និងឯកសារ E367/5.1.13 (១០ ខែ) ។

[43] ប្រតិចារឹក ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ទំព័រ ១០៥។

សន្និដ្ឋាន និងជំនាញរបស់គាត់ត្រូវបានវិភាគដោយអ្នកដទៃនៅក្នុងប្រភពដែលគេស្គាល់ជាទូទៅ ក្នុងនោះរួមទាំង កាសែត និងទិនានុប្បវត្តិសិក្សាស្រាវជ្រាវនានា។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ឯកសារដែលបានស្នើឡើយទាក់ទងនឹងសម្ភារៈដែលមាននៅក្នុងសំណុំរឿងរួចហើយគឺសៀវភៅចំនួនពីរក្បាលរបស់លោក ឧស្មាន ដែលមានចំណងជើងថា "Oukoubah" និង "ការបះបោររបស់ជនជាតិចាម" ដែលត្រូវបានទទួលយកធ្វើជាឯកសារភស្តុ-តាងដាច់ដោយឡែកពីគ្នា គឺឯកសារ E3/1822 និងឯកសារ E3/2653 ។ អាស្រ័យហេតុនេះ អង្គ-ជំនុំជម្រះយល់ឃើញថា ជាការសមស្របដែលត្រូវវាយតម្លៃរួមគ្នាជាមួយនឹងឯកសារផ្សេងៗ ដែលត្រូវបានស្នើឡើងជាមួយនឹងភស្តុតាងដែលត្រូវបានលើកឡើងខាងលើ ។ ក្រោយពីពិចារណាទៅលើចំណុចខាងលើរួចមក ទោះបីជាសំណើសុំលើកទីមួយពុំត្រូវបានដាក់ទាន់ពេលវេលាកំណត់ក៏ដោយ ក៏ផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យទទួលយកឯកសារទាំងដប់នេះ។

១៦. ចំពោះឯកសារផ្សេងៗទៀតដែលនៅសេសសល់ក្នុងសំណើសុំលើកទីមួយ អង្គជំនុំជម្រះពិចារណាឃើញថា ឯកសារទាំងនោះពុំទាក់ទងនឹងសំណុំរឿង ០០២/០២ ឡើយ ដោយសារឯកសារទាំងនេះពុំទាក់ទងដោយផ្ទាល់ទៅនឹងសាវតារផ្ទាល់ខ្លួន ឬ ជំនាញរបស់លោក ឧស្មាន (ឯកសារ E367/4.1.2) ឬក៏ថា ឯកសារទាំងនេះ គឺជាសេចក្ដីសង្ខេបព័ត៌មានទូទៅ និងជាន់គ្នា ដែលជាប់ទាក់ទងបន្តិចបន្តួចទៅនឹងការប្រព្រឹត្តលើជនជាតិចាម និង/ឬ ជាឯកសារដែលយោងទៅប្រភពព័ត៌មានមិនផ្ទាល់ (ឯកសារ E367/4.1.5 ឯកសារ E367/4.1.8 ឯកសារ E367/4.1.13 ដល់ឯកសារ E367/4.1.15)។ យោងតាមហេតុផលទាំងនេះ ឯកសារទាំងប្រាំនៅក្នុងសំណើសុំលើកទីមួយត្រូវច្រានចោល។

**<u>៣.២. សំណើសុំលើកទីពីរ</u>**

១៧. អង្គជំនុំជម្រះពិចារណាឃើញថា ឯកសារ E367/5.1.1 ឯកសារ E367/5.1.2 និងឯកសារ E367/5.1.6 ដល់ឯកសារ E367/5.1.12 គឺជាប់ទាក់ទងទៅនឹងសំណុំរឿង ០០២/០២ ពីព្រោះ ឯកសារទាំងនេះអាចផ្ដល់ភស្តុតាងដោះបន្ទុក ។ ព័ត៌មាននេះទាក់ទងនឹងខ្មែរស និងការបះបោរប្រឆាំងនឹងខ្មែរ ការប្រឆាំងផ្នែកនយោបាយរបស់សហគមន៍ជនជាតិចាមដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងខ្មែរក្រហមដែលជាមូលហេតុនៃការកំណត់គោលដៅលើពួកគេ ការទំនាក់ទំនងរបស់ជនជាតិចាមជាមួយនឹងសហគមន៍មូស្លីមផ្សេងទៀតនៅក្រៅប្រទេស និងកិច្ចខិតខំប្រឹងប្រែងផ្នែកការទូត

របស់មេដឹកនាំជនជាតិចាមក្នុងការចូលរួមនៅក្នុងសន្និសីទអ៊ីស្លាមនៃទីក្រុងកូឡាឡាំពួរ នៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ លើសពីនេះទៀត ឯកសារ E367/5.1.2 ត្រូវបានលើកឡើងនៅក្នុងសៀវភៅមួយក្បាលក្នុងចំណោមសៀវភៅរបស់លោក ឧស្មាន ដែលត្រូវបានទទួលយករួចហើយ គឺឯកសារ E3/1822 ។ អង្គជំនុំជម្រះយល់ឃើញថា ឯកសារទាំងនេះ អាចទុកចិត្តបានដោយសារវាមានប្រភពចេញមកពីលោក ឧស្មាន (ឯកសារ E367/5.1.1) ឯកសារទាំងនេះត្រូវបានលើកឡើងនៅក្នុងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះរួចហើយ (ឯកសារ E367/5.1.2) ឬ ក្នុងករណីសារទូរលេខការទូត ត្រូវបានទទួលមកពីប្រភពដែលគេស្គាល់ទូទៅ។

១៨. ទាក់ទងនឹងចម្លើយសារភាពនៅ ស-២១ របស់ ចឹក ប្រាហ៊ីម (ឯកសារ E367/5.1.2) ដែលមានតែចំណុចដកស្រង់ខ្លះនៃឯកសារនេះដែលត្រូវបានស្នើសុំឱ្យទទួលយកនោះ អង្គជំនុំជម្រះពិចារណាឃើញថា ជាការសមស្របក្នុងការទទួលយកឯកសារនេះទាំងស្រុងតែម្តង ដើម្បីឱ្យភាគី និងអង្គជំនុំជម្រះយល់អំពីបរិបទនៃភ័ស្តុតាងដែលត្រូវបានទទួលយក។ អង្គជំនុំជម្រះកត់សម្គាល់ការជំទាស់របស់សហព្រះរាជអាជ្ញាអន្តរជាតិ និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងការទទួលយកឯកសារមួយនេះ ដោយផ្អែកលើមូលដ្ឋានថា ឯកសារនេះគឺជាចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសូមរំឭកថា ភ័ស្តុតាងដែលទទួលបានមកពីទារុណកម្មអាចត្រូវបានយកមកពិចារណា ក្នុងគោលបំណងមួយចំនួនតូចដែលបានកំណត់តែប៉ុណ្ណោះ ។ ទោះបីជាយ៉ាងនេះក្តី ចំណុចនេះពុំរារាំងដល់ការទទួលយកភ័ស្តុតាងបែបនេះ ក្នុងករណីដែលភ័ស្តុតាងនេះត្រូវស្នើសុំឱ្យប្រើប្រាស់ជាភ័ស្តុតាងប្រឆាំងនឹងបុគ្គលដែលត្រូវបានចោទប្រកាន់អំពីអំពើទារុណកម្ម[44]។ ក្រោយពីពិចារណាលើចំណុចទាំងនេះរួចមក ទោះបីជាសំណើសុំលើកទីពីរពុំត្រូវបានដាក់ទាន់ពេលវេលាកំណត់ក៏ដោយ ក៏ផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យទទួលយកឯកសារខាងលើនេះបានដែរ។

១៩. ចំពោះឯកសារដែលនៅសេសសល់ចំនួនប្រាំទៀតនៅក្នុងសំណើសុំលើកទីពីរ អង្គជំនុំជម្រះពិចារណាឃើញថា ឯកសារទាំងនេះជាន់គ្នា (ឯកសារ E367/5.1.3 និងឯកសារ E367/5.1.13) ឬ ថាឯកសារទាំងនេះ គឺជាសេចក្តីសង្ខេបនៃព័ត៌មានទូទៅផ្សេងទៀត (ឯកសារ E367/5.1.3 និងឯកសារ E367/5.1.14) ឯកសារទាំងនេះមានព័ត៌មានដែលស្ថិតនៅក្រៅវិសាលភាពពេលវេលានៃ

[44] សេចក្តីសម្រេចលើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ឯកសារ E350/8 ទំព័រ ៣៣-៣៤។

ការជំនុំជម្រះ (ឯកសារ E367/5.1.4) ឬ បើមិនដូច្នោះទេ ពុំជាប់ទាក់ទង និងយោងទៅប្រភពដទៃៗទៀត (ឯកសារ E367/5.1.5) ។ សំណើសុំលើកទីពីរត្រូវបានច្រានចោលដោយផ្អែកលើមូលដ្ឋាននេះ។

២០. ចំណុចចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ឯកសារទាំងអស់ដែលត្រូវបានស្នើសុំឱ្យទទួលយកនៅក្នុងសំណើសុំលើកទីមួយ និងលើកទីពីរ ត្រូវបានដាក់តែមួយភាសាក្នុងចំណោមភាសាប្រើប្រាស់ជាផ្លូវការនៅ អ.វ.ត.ក។ ដូច្នេះ ការទទួលយកឯកសារទាំងនេះមកធ្វើជាឯកសារភ័ស្តុតាងតម្រូវឱ្យមានឯកសារបកប្រែជាភាសាអង់គ្លេស និង/ឬ ភាសាបារាំង និង/ឬ ភាសាខ្មែរ។ ឯកសារ E367/4.1.1 ឯកសារ E367/4.1.4 ឯកសារ E367/4.1.9 ឯកសារ E367/4.1.10 និង ឯកសារ E367/4.1.11 ត្រូវបានបកប្រែទៅជាភាសាខ្មែររួចហើយ។ ត្រង់ចំណុចនេះ អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីទាំងអស់ដើម្បីធានាថា ឯកសារភ័ស្តុតាងដែលត្រូវបានទទួលយក ត្រូវមានជាភាសាផ្លូវការទាំងបីរបស់ អ.វ.ត.ក[45]។

**ផ្អែកលើសំអាងហេតុដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូង÷**

**យល់ព្រមតាមផ្នែកខ្លះនៃសំណើសុំលើកទីមួយ**

**ទទួលយក**ឯកសារដូចខាងក្រោមនៅក្នុងសំណើសុំលើកទីមួយ និងកំណត់លេខ E3 ដូចបានបង្ហាញនៅក្នុងសញ្ញាវង្វង់ក្រចក៖

- ឯកសារ E367/4.1.1 (ឯកសារ E3/9678)
- ឯកសារ E367/4.1.3 (ឯកសារ E3/9679)
- ឯកសារ E367/4.1.4 (ឯកសារ E3/9680)
- ឯកសារ E367/4.1.6 (ឯកសារ E3/9681)
- ឯកសារ E367/4.1.7 (ឯកសារ E3/9682)
- ឯកសារ E367/4.1.9 (ឯកសារ E3/9683)
- ឯកសារ E367/4.1.10 (ឯកសារ E3/9684)
- ឯកសារ E367/4.1.11 (ឯកសារ E3/9685)

---

[45] សាលក្រមលើសំណុំរឿង ០០២/០១ ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313, កថាខណ្ឌ ៣៦។

01238617



- ឯកសារ E367/4.1.12 (ឯកសារ E3/9686)

**ច្រានចោល**ឯកសារខាងក្រោម នៅក្នុងសំណើសុំលើកទីមួយ៖

- ឯកសារ E367/4.1.2
- ឯកសារ E367/4.1.5
- ឯកសារ E367/4.1.8
- ឯកសារ E367/4.1.13
- ឯកសារ E367/4.1.14
- ឯកសារ E367/4.1.15

**យល់ព្រម**តាមផ្នែកខ្លះនៅក្នុងសំណើសុំលើកទីពីរ។

**ទទួលយក**ឯកសារខាងក្រោមនៅក្នុងសំណើសុំលើកទីពីរ និងកំណត់លេខ E3 ដូចបានបង្ហាញនៅក្នុងសញ្ញារង្វង់ក្រចក៖

- ឯកសារ E367/5.1.1 (ឯកសារ E3/9687)
- ឯកសារ E367/5.1.2 (ឯកសារ E3/9688) (ឯកសារនេះត្រូវបានទទួលយកទាំងស្រុងតែម្តង)
- ឯកសារ E367/5.1.6 (ឯកសារ E3/9689)
- ឯកសារ E367/5.1.7 (ឯកសារ E3/9690)
- ឯកសារ E367/5.1.8 (ឯកសារ E3/9691)
- ឯកសារ E367/5.1.9 (ឯកសារ E3/9692)
- ឯកសារ E367/5.1.10 (ឯកសារ E3/9693)
- ឯកសារ E367/5.1.11 (ឯកសារ E3/9694)
- ឯកសារ E367/5.1.12 (ឯកសារ E3/9695)

**ច្រានចោល**ឯកសារខាងក្រោម នៅក្នុងសំណើសុំលើកទីពីរ៖

- ឯកសារ E367/5.1.3
- ឯកសារ E367/5.1.4
- ឯកសារ E367/5.1.5

- ឯកសារ E367/5.1.13
- ឯកសារ E367/5.1.14

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦

ប្រធានអង្គជំនុំជម្រះសាលាដំបូង

 និល ណុន